# នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០៤/២/០៧-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក

ភាគីដាក់ឯកសារ៖ មេធាវីការពារក្តីរបស់ មាស មុត

ដាក់ជូន៖ អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម៖ អង់គ្លេស

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ២៩ ខែឧសភា ឆ្នាំ ២០២០

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 19-Jun-2020, 15:30
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ៖ **សាធារណៈ**/Public

ចំណាត់ថ្នាក់ប្រភេទឯកសារ៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

## សំណើរបស់ មាស មុត សុំធ្វើអន្តរាគមន៍ និង ឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខជាបន្ទាន់របស់ សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការរំលត់ជាធរមាននៃសំណុំរឿង ០០៤/២ របស់ អង្គជំនុំជម្រះសាលាដំបូង

---

**ដាក់ដោយ** ÷

**សហមេធាវី** ៖

អាង ឧត្តម

Michael G. KARNAVAS

**ផ្ញើជូន** ÷

**ចៅក្រមអង្គជំនុំជម្រះតុលាការកំពូល** ៖

ចៅក្រម គង់ ស្រ៊ីម ប្រធាន

ចៅក្រម C. N. JAYASINGHE

ចៅក្រម សោម សិរីវឌ្ឍ

ចៅក្រម Florence Ndepele MUMBA

ចៅក្រម ម៉ុង មុន្នីចរិយា

ចៅក្រម Maureen HARDING CLARK

ចៅក្រម យ៉ា ណារិន

០០៤/២/០៧-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោកស្រី Brenda J. HOLLIS

**ក្រុមមេធាវីការពារក្តីទាំងអស់នៅក្នុងរឿងក្តី ០០៤/២, ០០៣ និង ០០៤**

**ភាគីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នៅក្នុងរឿងក្តី ០០៤/២, ០០៣ និង ០០៤**

សំណើរបស់ មាស មុត សុំធ្វើអន្តរាគមន៍ និង ឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខជាបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការរំលត់ជាធរមាននៃសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង

លោក មាស មុត តាមរយៈសហមេធាវីរបស់គាត់ ("មេធាវីការពារក្តី") តាមរយៈនេះ ស្នើសុំធ្វើកិច្ចអន្តរាគមន៍ និង ឆ្លើយតបនឹងទទ្បីករណ៍ដោយឡែកនៅក្នុងបណ្តឹងសាទុក្ខជាបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការរំលត់ជាធរមាននៃសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង ("បណ្តឹងសាទុក្ខជាបន្ទាន់របស់ ស.ព.អ.") ដែលជាទូទៅ អាចនឹងប៉ះពាល់ដល់រឿងក្តី ០០៣ ដូចដែល ស.ព.អ. បានទទួលស្គាល់យ៉ាងត្រឹមត្រូវនៅក្នុងសំអាងហេតុ មួយផ្នែក ថា វាចាំបាច់ត្រូវការកិច្ចអន្តរាគមន៍ពីអង្គជំនុំជម្រះតុលាការកំពូល ("អ.ជ.ត.ក.")[1]។ ការអនុញ្ញាតឲ្យលោក មាស មុត ធ្វើអន្តរាគមន៍ មិនមែនត្រឹមតែមានយុត្តិធម៌ និង សមធម៌នោះទេ ប៉ុន្តែថែមទាំងជាប្រយោជន៍នៃយុត្តិធម៌ផងដែរ ដោយយល់ឃើញថា ករណីនេះនឹងជាឱកាសតែមួយគត់សម្រាប់គាត់ធ្វើដូច្នេះនោះគឺ៖ វានឹងលើកកម្ពស់សច្ចភាពផ្លូវច្បាប់ និង សេដ្ឋកិច្ចតុលាការ ដោយពុំមានផលប៉ះពាល់ដល់សហព្រះរាជអាជ្ញា ឬ ដើមបណ្តឹងរដ្ឋប្បវេណីឡើយ ហើយវានឹងជួយគ្រប់ភាគីទាំងអស់ក្នុងការសម្រេចថា តើគួរចាំបាច់ត្រូវដាក់សារណាសុំការពិចារណានាពេលខាងមុខ និង មានវេទិកាសមស្របសម្រាប់សារណាសុំការពិចារណាបែបនេះឬទេ។

## I. សំណើសុំធ្វើអន្តរាគមន៍

*<u>ការអន្តរាគមន៍អាចធ្វើទៅបាន នៅពេលសេចក្តីសម្រេចមួយនឹងប៉ះពាល់ដល់ភាគីនៅក្នុងរឿងក្តីផ្សេងទៀត</u>*

១. ការអន្តរាគមន៍ដោយភាគីមួយទៅក្នុងរឿងក្តីរបស់ភាគីមួយទៀតអាចអនុញ្ញាតធ្វើទៅបាន "ទៅតាមករណីជាក់ស្តែងនីមួយៗ នៅពេលដែលផលប្រយោជន៍នៃយុត្តិធម៌តម្រូវឲ្យធ្វើដូច្នេះ"[2]។ "បញ្ហាដែលត្រូវពិចារណាជាបឋមក្នុងការអនុញ្ញាតឲ្យធ្វើបទអន្តរាគមន៍ គឺថាតើបទអន្តរាគមន៍នេះគឺជាផល

[1] *រឿងក្តី អោ អាន* សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក បណ្តឹងសាទុក្ខជាបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការរំលត់ជាធរមាននៃសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ៤ ខែឧសភា ឆ្នាំ ២០២០ ឯកសារ E004/2/1 ("បណ្តឹងសាទុក្ខជាបន្ទាន់របស់ ស.ព.អ.") កថាខណ្ឌ ៤, ៤៨, ៦១។

[2] *រឿងក្តី នួន ជា និង ជនផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក សេចក្តីសម្រេចលើសំណើសុំធ្វើអន្តរាគមន៍ ឬ សុំដាក់សារណារបស់*អ្នកមិនមែនជាភាគីនៃរឿងក្តី* នៅក្នុងកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី ៨ ខែមេសា ឆ្នាំ ២០១៥ ឯកសារ F20/1 កថាខណ្ឌ ១២។

ប្រយោជន៍ស្របច្បាប់របស់ស្ថាប័នដែលស្នើសុំនោះ ហើយបើត្រូវបានបដិសេធវិញនោះ ថាតើអាចរងផលប៉ះពាល់ដែរឬយ៉ាងណា"[3]។

២. ពីមុន អង្គជំនុំជម្រះ អ.វ.ត.ក. បានអនុញ្ញាតឱ្យធ្វើអន្តរាគមន៍ កាលណាបញ្ហានោះស្ថិតក្រោមការពិចារណា គឺជាករណីមួយដែលធ្វើឱ្យប៉ះពាល់ដល់ភាគីនានានៅក្នុងរឿងក្តីផ្សេងទៀត។ អង្គបុរេជំនុំជម្រះ ("អ.ប.ជ.") បានអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងរឿងក្តី ០០១ ដាក់សារណាសុំការពិចារណាលើពាក្យស្នើសុំ ដែលបានធ្វើឡើងនៅក្នុងរឿងក្តី ០០២ ដោយផ្អែកលើមូលដ្ឋានថា ការចេញសេចក្តីសម្រេចលើពាក្យស្នើសុំ នឹងនាំដល់ការចេញសេចក្តីបង្គាប់ជាទូទៅលើសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលមិនមានមេធាវីតំណាង ក្នុងការថ្លែងប្រាស្រ័យជូន អ.ប.ជ. ហើយដូច្នេះ វាអាចនឹងប៉ះពាលដល់ដើមបណ្តឹងរដ្ឋប្បវេណីទាំងនៅក្នុងរឿងក្តី ០០១ និង រឿងក្តី ០០២[4]។

៣. នៅក្នុងរឿងក្តី ០០៣ និង រឿងក្តី ០០៤ សហចៅក្រមស៊ើបអង្កេត ("ស.ច.ស.") បានទទួលស្គាល់អំពីសារៈសំខាន់ ក្នុងការមានសារណាសុំការពិចារណារបស់ភាគីស្តីពីស្ថានភាពថវិការបស់ អ.វ.ត.ក. និង ផលប៉ះពាល់លើរឿងក្តី ០០៣ រឿងក្តី ០០៤ និង រឿងក្តី ០០៤/២ បន្ថែមលើសារណាសុំការពិចារណារបស់ការិយាល័យរដ្ឋបាល មុនពេលសម្រេចថា តើត្រូវចេញដីកាផ្អាកដំណើរការនីតិវិធីជាអចិន្ត្រៃយ៍ឬយ៉ាងណា[5]។ ស្រដៀងគ្នានេះ អ.ជ.ត.ក. គួរទទួលស្គាល់ថា ផលប៉ះពាល់នៃសេចក្តីសម្រេចលើបណ្តឹងសាទុក្ខជាបន្ទាន់របស់ ស.ព.អ. នឹងកើតមានចំពោះរឿងក្តី ០០៣ និង រឿងក្តី ០០៤ ហើយគួរអនុញ្ញាតឱ្យមានសារណាសុំការពិចារណាទៅលើបញ្ហានេះពីភាគី *ទាំងអស់*ដែលពាក់ព័ន្ធផលប្រយោជន៍។

---

[3] *រឿងក្តី នួន ជា និង ជនផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក សេចក្តីសម្រេចលើសំណើសុំធ្វើអន្តរាគមន៍ ឬ សុំដាក់សារណារបស់*អ្នកមិនមែនជាភាគីនៃរឿងក្តី* នៅក្នុងកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី ៨ ខែមេសា ឆ្នាំ ២០១៥ ឯកសារ F20/1 កថាខណ្ឌ ១១។

[4] *សូមមើល រឿងក្តី នួន ជា និង ជនផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អបជ០២) សេចក្តីសម្រេចលើសំណើរបស់លោក អៀង សារី សុំដាក់អំណះអំណាងស្តីពីការអនុវត្តន៍ទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួម នៅក្នុងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជំទាស់ទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណីរបស់ កាំង ហ្កេកអ៊ាវ "ឌុច" ចុះថ្ងៃទី ៦ ខែតុលា ឆ្នាំ ២០០៨ ឯកសារ D99/3/19 កថាខណ្ឌ ១១ យោងទៅលើសេចក្តីបង្គាប់ចំពោះដើមបណ្តឹងរដ្ឋប្បវេណី ដែលជាឯកសារសម្ងាត់។

[5] សំណើសុំមតិយោបល់អំពីស្ថានភាពថវិការបស់ អ.វ.ត.ក. និង ផលប៉ះពាល់មកលើសំណុំរឿង ០០៣ សំណុំរឿង ០០៤ និង សំណុំរឿង ០០៤/២ ចុះថ្ងៃទី ៥ ខែឧសភា ឆ្នាំ ២០១៧ ឯកសារ D249 កថាខណ្ឌ ៨៥។

៤. សាលាក្ដីអន្តរជាតិដទៃៗទៀតបានអនុញ្ញាតឲ្យធ្វើអន្តរាគមន៍ នៅពេលសេចក្ដីសម្រេចមួយអាចនឹងប៉ះពាល់ដល់ផលប្រយោជន៍របស់ជនជាប់ចោទផ្សេងទៀតនៅចំពោះមុខសាលាក្ដី។ នៅតុលាការពិសេសសម្រាប់សេរ៉ាឡេអូន ("តុលាការ SCSL") អង្គជំនុំជម្រះតុលាការកំពូលបានអនុញ្ញាតឲ្យ Augustine Gbao និង Moinina Fofana ធ្វើអន្តរាគមន៍នៅក្នុងរឿងក្ដី *រដ្ឋអាជ្ញា ទល់នឹង Kallon & Kamara* ពាក់ព័ន្ធនឹងភាពអនុវត្តបាននៃការលើកលែងទោស Lomé Accord[6]។ អង្គជំនុំជម្រះតុលាការកំពូលក៏បានអនុញ្ញាតឲ្យ Moinina Fofana ធ្វើអន្តរាគមន៍លើបញ្ហាពីរនៅក្នុងរឿងក្ដី *រដ្ឋអាជ្ញា ទល់នឹង Norman* ពាក់ព័ន្ធនឹងយុត្តាធិការរបស់តុលាការ SCSL ក្នុងការចោទប្រកាន់ជនជាប់ចោទចំពោះការជ្រើសរើសកុមារ[7] និង ឯករាជ្យតុលាការរបស់តុលាការ SCSL[8]។ ការអន្តរាគមន៍របស់តតីយភាគីនៅក្នុងបណ្ដឹងសាទុក្ខរឿងក្ដីព្រហ្មទណ្ឌ ក៏ជារឿងធម្មតានៅតាមសាលាក្ដីក្នុងស្រុកផងដែរ[9]។

---

[6] *សូមមើល រឿងក្ដី រដ្ឋអាជ្ញា ទល់នឹង Kallon និង Kallon* សំណុំរឿងលេខ SCSL-2004-15-AR72(E) សេចក្ដីសម្រេចលើការជំទាស់តវ៉ាអំពីយុត្តាធិការ៖ កិច្ចព្រមព្រៀងលើកលែងទោស Lomé (Lomé Accord Amnesty) ចុះថ្ងៃទី ១៣ ខែមីនា ឆ្នាំ២០០៤ ទំព័រវាយឈ្មោះចំណងជើង (ដែលរៀបរាប់ថាឈ្មោះ Gbao និង Fofana ជាអ្នកធ្វើអន្តរាគមន៍) និង ទំព័រ ៣ ដែលកត់សម្គាល់ថា Gbao និង Fofana បានដាក់សារណាសុំការពិចារណាជាលាយលក្ខណ៍អក្សរ និង ត្រូវបានអនុញ្ញាតឲ្យធ្វើអន្តរាគមន៍នៅក្នុងសវនាការសួរដេញដោល។

[7] *សូមមើល រឿងក្ដី រដ្ឋអាជ្ញា ទល់នឹង Norman* សំណុំរឿងលេខ SCSL-2004-14-AR72(E) សេចក្ដីសម្រេចលើញត្តិបឋមដោយផ្អែកលើកង្វះយុត្តាធិការ (ការជ្រើសរើសកុមារ) ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០០៤ ទំព័រវាយឈ្មោះចំណងជើង (ដែលរៀបរាប់ថាឈ្មោះ Fofana ជាអ្នកធ្វើអន្តរាគមន៍) និង ទំព័រ ៣ ដែលកត់សម្គាល់ថា Fofana បានដាក់សារណាសុំការពិចារណាជាលាយលក្ខណ៍អក្សរ និង ត្រូវបានអនុញ្ញាតឲ្យធ្វើអន្តរាគមន៍ នៅក្នុងសវនាការសួរដេញដោល។

[8] *រឿងក្ដី រដ្ឋអាជ្ញា ទល់នឹង Norman* សំណុំរឿងលេខ SCSL-2004-14-AR72(E) សេចក្ដីសម្រេចលើញត្តិបឋមដោយផ្អែកលើកង្វះយុត្តាធិការ (ឯករាជភាពតុលាការ) ចុះថ្ងៃទី ១៣ ខែមីនា ឆ្នាំ ២០០៤ ទំព័រវាយឈ្មោះចំណងជើង (ដែលរៀបរាប់ថាឈ្មោះ Fofana ជាអ្នកធ្វើអន្តរាគមន៍)។

[9] ឧទាហរណ៍ នៅប្រទេសកាណាដា "ការអន្តរាគមន៍ពីតតីយភាគី បានក្លាយជាបទដ្ឋាន ជាជាងករណីលើកលែងនៅក្នុងរឿងក្ដីនៅចំពោះតុលាការកំពូលប្រទេសកាណាដា" ដែលការអន្តរាគមន៍ពីតតីយភាគី កំពុងត្រូវបានស្វាគមន៍ និង ជំរុញឲ្យមាន ដូច្នេះតុលាការអាចនឹងទទួលបានព័ត៌មាន ទឡ្ហីករណ៍ និង ទស្សនៈខុសៗគ្នាយ៉ាងទូលំទូលាយបំផុត ដែលខ្លួនអាចនឹងប្រើ នៅពេលធ្វើសេចក្ដីសម្រេចចិត្ត។ ការអន្តរាគមន៍នេះ ក៏កំពុងតែមានលក្ខណៈទៀងទាត់ នៅចំពោះមុខសភាជាន់ខ្ពស់ (the House of Lords) ក្នុងចក្រភពអង់គ្លេស។ Andrea C. Loux *ការស្ដាប់ "សំឡេងខុសគ្នា"៖ ការអន្តរាគមន៍ពីតតីយភាគីនៅក្នុងបណ្ដឹងសាទុក្ខរឿងក្ដីព្រហ្មទណ្ឌ* ៥៣(១) បញ្ហាផ្លូវច្បាប់នាបច្ចុប្បន្ន ៤៤៩, ៤៥២-៥៤ (ឆ្នាំ ២០០០)។

## *ផលប្រយោជន៍នៃយុត្តិធម៌ និង សេដ្ឋកិច្ចតុលាការអនុគ្រោះដល់ការអនុញ្ញាតឲ្យធ្វើអន្តរាគមន៍*

៥. វាជាប្រយោជន៍នៃយុត្តិធម៌[10] ដែលអនុញ្ញាតឲ្យមេធាវីការពារក្តីធ្វើអន្តរាគមន៍នៅក្នុងរឿងក្តី ០០៤/២ តាមរយៈការដាក់សារណាសុំការពិចារណាជាលាយល័ក្ខអក្សរ ក្នុងការឆ្លើយតបទៅនឹងទឡ្ហីករណ៍ដោយឡែកនៅក្នុងបណ្តឹងសាទុក្ខជាបន្ទាន់របស់ ស.ព.អ. ដែលមេធាវីការពារក្តីសុំឲ្យពិចារណាថា អ.ជ.ត.ក. ពុំមានយុត្តាធិការនឹងធ្វើសវនាការ ហើយគួរតែច្រានចោល[11]។ លោក មាស មុត មានផលប្រយោជន៍ស្របច្បាប់នៅក្នុងបញ្ហានេះ និង គួរត្រូវបានអនុញ្ញាតឲ្យធ្វើកិច្ចអន្តរាគមន៍ ព្រោះក្រែងលោគាត់ត្រូវរងការខូចខាត ហើយសិទ្ធិរបស់គាត់ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ និង ដំណើរការសមស្រប ត្រូវរងព្យសនកម្មដែលពុំអាចជួសជុលបាន[12]។ ការអន្តរាគមន៍ត្រូវធ្វើឡើងជាចាំបាច់ ដោយសារថា ដូច ស.ព.អ. បានចង្អុលបញ្ជាក់យ៉ាងត្រឹមត្រូវថា សេចក្តី

---

[10] *រឿងក្តី នួន ជា និង ជនផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក សេចក្តីសម្រេចលើសំណើសុំធ្វើអន្តរាគមន៍ ឬ សុំដាក់សារណារបស់*អ្នកមិនមែនជាភាគីនៃរឿងក្តី* នៅក្នុងកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី ៨ ខែមេសា ឆ្នាំ ២០១៥ ឯកសារ F20/1 កថាខណ្ឌ ១២។

[11] *សូមមើល* កថាខណ្ឌ ១០-១១ *ខាងក្រោម*។

[12] *រឿងក្តី នួន ជា និង ជនផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក សេចក្តីសម្រេចលើសំណើសុំធ្វើអន្តរាគមន៍ ឬ សុំដាក់សារណារបស់*អ្នកមិនមែនជាភាគីនៃរឿងក្តី* នៅក្នុងកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី ៨ ខែមេសា ឆ្នាំ ២០១៥ ឯកសារ F20/1 កថាខណ្ឌ ១១។ មាត្រា ១២(២) នៃកិច្ចព្រមព្រៀង និង មាត្រា ៣៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ចែងថា កិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក. ត្រូវប្រព្រឹត្តទៅឲ្យស្របនឹង "បទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និង ដំណើរការសមស្របនៃច្បាប់" ដូចដែលមានចែងក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ដែលត្រូវបានទទួលស្គាល់នៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជា។ វិធាន ២១ តម្រូវឲ្យ អ.ជ.ត.ក. បកស្រាយក្របខណ្ឌ អ.វ.ត.ក. ក្នុងន័យការពារជានិច្ចដល់សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់លោក មាស មុត។ *សូមមើល* មាត្រា ១២ (២) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និង រាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ២០០៣) ("កិច្ចព្រមព្រៀង")។ មាត្រា ៣៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។ វិធាន ២១ នៃវិធានផ្ទៃក្នុង។ មាត្រា ១៤(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលបានអនុម័ត និង បើកចំហឲ្យចុះហត្ថលេខា ផ្តល់សច្ចាប័ន និង ចូលជាសមាជិក តាមរយៈសេចក្តីសម្រេចរបស់មហាសន្និបាត អ.ស.ប លេខ 2200A (XXI) ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ១៩៦៦ ដែលចូលជាធរមាននៅថ្ងៃទី ២៣ ខែមីនា ឆ្នាំ ១៩៧៦ តាមមាត្រា ៤៩។ មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ ដែលបានកែប្រែដោយក្រម ចុះថ្ងៃទី ៨ ខែមីនា ឆ្នាំ១៩៩៩ ប្រកាសឲ្យប្រើវិសោធនកម្មលើមាត្រា ១១, ១២, ១៣, ១៨, ២២, ២៦, ២៨, ៣០, ៣៤, ៥១, ៩០, ៩១, ៩៣ ព្រមទាំងមាត្រាដទៃទៀតចាប់ពីជំពូក ៨ ដល់ជំពូក ១៤ នៃរដ្ឋធម្មនុញ្ញ ព្រះរាជាណាចក្រកម្ពុជា ដែលបានអនុម័តដោយរដ្ឋសភាជាតិកាលពីថ្ងៃទី ៤ ខែមីនា ឆ្នាំ ១៩៩៩។

សម្រេចលើអង្គច្បាប់ដែលលើកឡើងដោយ ស.ព.អ. នឹងមានអនុភាព *ប្រកាន់តាមអ្វីដែលសម្រេចកន្លងមក* "ទុកជាយុត្តិសាស្ត្រ ... សម្រាប់កាលៈទេសៈនីតិវិធីស្រដៀងគ្នានេះ ដែលទំនងជាអាចកើតមានឡើងនៅក្នុងរឿងក្តី ០០៣ និង ០០៤"[13]។

៦. វាជាប្រយោជន៍នៃសេដ្ឋកិច្ចតុលាការ ក្នុងការអនុញ្ញាតឲ្យមេធាវីការពារក្តីធ្វើអន្តរាគមន៍។ ការអន្តរាគមន៍នៅដំណាក់កាលនេះ នឹងបន្ថយចំនួនសារណាសុំការពិចារណាដែលនឹងដាក់ និង សវនាការផ្ទាល់មាត់ ដែលនឹងរៀបចំឡើងនាពេលចុងក្រោយនៅចំពោះមុខ អ.ជ.ត.ក. ឬ អង្គជំនុំជម្រះណាផ្សេងទៀត ដូច្នេះ វាធ្វើឲ្យដំណើរការនីតិវិធីកាន់តែមានប្រសិទ្ធភាព។ អ.ជ.ត.ក. នឹងសម្រេចបានប្រសើរបំផុត នៅពេលមានទទ្បីករណ៍សក្តានុពលទាំងអស់នៅចំពោះមុខខ្លួននាពេលនេះ - រួមទាំងទឡ្ហីករណ៍របស់ភាគីផ្សេងទៀតដែលមិនមែនជាភាគីនៅក្នុងរឿងក្តី ០០៤/២ - មុនពេលធ្វើសេចក្តីសម្រេច។

៧. អន្តរាគមន៍ដោយមេធាវីការពារក្តី នឹងមិនធ្វើឲ្យខូចខាតដល់ភាគីនានានៃរឿងក្តី ០០៤/២ ឡើយ។ សារណាសុំការពិចារណារបស់មេធាវីការពារក្តីនឹងធានាថា អ.ជ.ត.ក. ទទួលបានទឡ្ហីករណ៍គ្រប់ជ្រុងជ្រោយអំពីអង្គច្បាប់ទាំងអស់ ដែលពាក់ព័ន្ធនឹងយុត្តាធិការរបស់ អ.ជ.ត.ក. ក្នុងការធ្វើសវនាការលើបណ្តឹងសាទុក្ខជាបន្ទាន់របស់ ស.ព.អ. (បញ្ហាអង្គច្បាប់ថ្មីហើយប្លែក ដែលមិនទាន់បានប្តឹងនៅឡើយ) ជាជាងការលើកឡើងដដែលៗ ការគាំទ្រ ឬ សារណាបន្ថែមទឡ្ហីករណ៍របស់ភាគីនៅក្នុងរឿងក្តី ០០៤/២[14]។

៨. អន្តរាគមន៍ដោយមេធាវីការពារក្តីនឹងមិនពន្យារការធ្វើសេចក្តីសម្រេចរបស់ អ.ជ.ត.ក. លើបណ្តឹងសាទុក្ខជាបន្ទាន់របស់ ស.ព.អ នោះទេ។ ស.ព.អ. បានដាក់បណ្តឹងសាទុក្ខជាបន្ទាន់កាលពីថ្ងៃទី ៤

---

[13] បណ្តឹងសាទុក្ខជាបន្ទាន់របស់ ស.ព.អ. កថាខណ្ឌ ៦១។

[14] *C.f. រឿងក្តី នួន ជា និង ជនផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក សេចក្តីសម្រេចលើសំណើសុំធ្វើអន្តរាគមន៍ ឬ សុំដាក់សារណារបស់*អ្នកមិនមែនជាភាគីនៃរឿងក្តី* នៅក្នុងកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី ៨ ខែមេសា ឆ្នាំ ២០១៥ ឯកសារ F20/1 កថាខណ្ឌ ១៤។ អ.ជ.ត.ក. បានបដិសេធបទអន្តរាគមន៍ពីមេធាវីការពារក្តីក្នុងរឿងក្តី ០០៣ និង ០០៤ ដោយសម្រេចថា ខ្លឹមសារនៃបទអន្តរាគមន៍ដែលបានស្នើឡើង ប្រាកដណាស់ អាចនឹងមានលក្ខណៈស្រដៀងគ្នាច្រើនទៅនឹងទឡ្ហីករណ៍ទាំងឡាយដែល នួន ជា និង ខៀវ សំផន ដោយពិចារណាទៅលក្ខណៈស្របនិង ត្រួតគ្នានៃផលប្រយោជន៍ដែលបានស្នើឡើង និង វិសាលភាពដែលប្រធានបទនៃរឿងក្តីនេះ ត្រូវបានជំទាស់តវ៉ារួចហើយនោះ។

ខែឧសភា ឆ្នាំ២០២០ ដែលត្រូវបានជូនដំណឹងជាផ្លូវការកាលពីថ្ងៃទី ១៩ ខែឧសភា ឆ្នាំ២០២០[15]។ មេធាវីការពារក្តី ពុំទាន់ទទួលបានការជូនដំណឹងអំពីចម្លើយតបរបស់ អោ អាន នៅឡើយទេ។ ការទទួលសារណាសុំការពិចារណារបស់មេធាវីការពារក្តីនាពេលនេះ នឹងមិនត្រូវការពេលវេលាបន្ថែមឡើយ មុនពេល អ.ជ.ត.ក. ចាប់ផ្តើមកិច្ចពិភាក្សាសម្រេចឡើយ។

## II. វិសាលភាពនៃអន្តរាគមន៍ដែលស្នើឡើង

៩. ប្រសិនបើអនុញ្ញាតឱ្យធ្វើអន្តរាគមន៍ នោះការអន្តរាគមន៍ដែលស្នើឡើង នឹងកម្រិតត្រឹមចម្លើយតបទៅនឹងទឡ្ហីករណ៍របស់ ស.ព.អ. ពាក់ព័ន្ធនឹងករណី ៖ **ក.** ថាតើ អ.ជ.ត.ក. មានយុត្តាធិការក្នុងការស្តាប់បណ្តឹងសាទុក្ខជាបន្ទាន់របស់ ស.ព.អ. ឬទេ[16] **ខ.** ថាតើគោលជំហរដើមដំបូង ដែលមានអត្ថិភាពនៅក្នុងក្របខណ្ឌ អ.វ.ត.ក. ដែលស្របតាមជំហរនេះ អង្គជំនុំជម្រះសាលាដំបូង ("អ.ជ.ស.ដ.") គួរបានរំកិលដំណើរការរឿងក្តីទៅជំនុំជម្រះឬទេ[17] និង **គ.** ថាតើ អ.ជ.ស.ដ. មានកំហុសក្នុងការមិនប្រើប្រាស់សិទ្ធិអំណាចពិសេស ដើម្បីពោលប្រាស្រ័យពីបញ្ហាណាមួយនៃបញ្ហានានានៅចំពោះមុខខ្លួនឬទេ[18]។

### ក. អ.ជ.ត.ក. ខ្វះយុត្តាធិការក្នុងការស្តាប់បណ្តឹងសាទុក្ខជាបន្ទាន់របស់ ស.ព.អ.

១០. ស.ព.អ. អះអាងថា អ.ជ.ត.ក. មានយុត្តាធិការក្នុងការស្តាប់បណ្តឹងសាទុក្ខជាបន្ទាន់របស់ខ្លួន អនុលោមតាមវិធាន ១០៤(៤)(ក) ឬ អនុលោមតាមយុត្តាធិការដែលជាប់ជាមួយ ដោយសារ៖ **ក.** អ.ជ.ស.ដ បានទទួលរឿងក្តី ០០៤/២ តាមផ្លូវច្បាប់[19] **ខ.** សេចក្តីថ្លែងការណ៍របស់ អ.ជ.ស.ដ ចុះថ្ងៃទី ៣ ខែមេសា ឆ្នាំ ២០២០[20] (ក្នុង) ភាពនៅស្ងៀមស្ងាត់ និង ការបង្វែរត្រឡប់វិញផ្ទាល់ដៃនូវ

---

[15] *រឿងក្តី អោ អាន* សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក ការចុះបញ្ជីបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ១៩ ខែឧសភា ឆ្នាំ ២០២០ ឯកសារ E004/2.1។

[16] បណ្តឹងសាទុក្ខជាបន្ទាន់របស់ ស.ព.អ. កថាខណ្ឌ ៤១-៤៩។

[17] បណ្តឹងសាទុក្ខជាបន្ទាន់របស់ ស.ព.អ. កថាខណ្ឌ ៥០-៥៧។

[18] បណ្តឹងសាទុក្ខជាបន្ទាន់របស់ ស.ព.អ. កថាខណ្ឌ ៥៨-៦១។

[19] បណ្តឹងសាទុក្ខជាបន្ទាន់របស់ ស.ព.អ. កថាខណ្ឌ ៤១។

[20] សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក. *សេចក្តីថ្លែងការណ៍របស់ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក. ស្តីពីសំណុំរឿង ០០៤/២ ពាក់ព័ន្ធនឹង អោ អាន* ចុះថ្ងៃទី ៣ ខែមេសា ឆ្នាំ ២០២០ គេហទំព័រ៖ https://www.eccc.gov.kh/

ឯកសារទាំងឡាយបានបង្កើតជា"សេចក្ដីសម្រេច" ដែលអាចប្ដឹងសាទុក្ខបាន ដែលមានអនុភាពបញ្ចប់ដំណើរការនីតិវិធី[21] និង **គ.** អ.ជ.ត.ក. គឺជា "ស្ថាប័ននីតិបុគ្គលតែមួយគត់ដែលអាចរក្សាសុចរិតភាពនៃដំណើរការនីតិវិធី ហើយដែលអាចការពារផលប្រយោជន៍យុត្តិធម៌"[22]។

១១. ប្រសិនបើអនុញ្ញាតឲ្យធ្វើអន្តរាគមន៍ មេធាវីការពារក្ដីនឹងស្នើសុំឲ្យពិចារណា ថា៖

ក. អ.ជ.ស.ដ. មិនដែលបានទទួលរឿងក្ដី ០០៤/២ ទេ ដោយសារតែពុំមានដីកាដំណោះស្រាយ។ ដីកាដំណោះស្រាយ ដែលបានចេញដោយខុសច្បាប់ មានវិការៈផ្នែកនីតិវិធី ដោយសារដីកាដំណោះស្រាយទាំងនោះ ត្រូវបានចេញដោយផ្ទុយនឹងវិធាន ៦៧(១)[23]។ វិធាន ៦៧(២) ពុំបានប្រមើលមើលទុកអំពីមោឃភាព ឬ ការរលត់ដីកាដំណោះស្រាយ ដែលមិនបានធ្វើឡើងស្របតាមក្របខណ្ឌ អ.វ.ត.ក. ដោយសារអ្នកព្រាងច្បាប់ពុំអាចប្រមើលមើលឃើញអំពី "ការចេញដីកាដំណោះស្រាយពីរផ្សេងគ្នា ផ្ទុយគ្នាក្នុងពេលតែមួយ ដែលមិនធ្លាប់មានពីមុនមក នៅក្នុងសំណុំរឿងតែមួយ"[24]។ ការបកស្រាយវិធាន ៦៧(២) រួមទាំង*ភាពចន្លោះប្រហោង*នៃវិធាននេះ ស្របតាមវិធាននៃការបកស្រាយតាមប្រព័ន្ធច្បាប់ស៊ីវិល និង ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែលនៅជាធរមាន ហើយនិងវិធាននីតិបង្កើតឡើងនៅកម្រិតអន្តរជាតិ បានគាំទ្រថា អនុភាពនៃការសម្រេចជាឯកឆ័ន្ទរបស់ អ.ប.ជ. នៅក្នុងរឿងក្ដី ០០៤/២ គឺថា ដីកាដំណោះស្រាយដែលខុសច្បាប់*ប្រាកដណាស់* គឺត្រូវបានចាត់ទុកជាមោឃៈ[25]។ ក្របខណ្ឌ អ.វ.ត.ក. កំណត់ថា ដីកាដំណោះស្រាយដែលមានវិការៈផ្នែកនីតិវិធីត្រូវទុកជាមោឃៈ និង ដកចេញពីក្នុងសំណុំរឿង[26]។

km/articles/secktiithlaengkaarnn-rpscaukrmqnggjmnumjmrhsaalaatmpuungnai-qvtk-stiibiismnnumryang-0042 ("សេចក្ដីថ្លែងរបស់ អ.ជ.ស.ដ. ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ ២០២០")។

[21] បណ្ដឹងសាទុក្ខជាបន្ទាន់របស់ ស.ព.អ. កថាខណ្ឌ ៤២-៤៤។

[22] បណ្ដឹងសាទុក្ខជាបន្ទាន់របស់ ស.ព.អ. កថាខណ្ឌ ៤៨។

[23] *រឿងក្ដី អោ អាន* សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អបជ៦០) សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ២០១៩ ឯកសារ D359/24 & D360/33 ("សេចក្ដីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្ដី ០០៤/២" ទំព័រ ៨៩-៩០។

[24] សេចក្ដីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្ដី ០០៤/២ កថាខណ្ឌ ៨៨។

[25] *សូមមើល* សារណាបន្ថែមរបស់ មាស មុត ទៅលើបណ្ដឹងឧទ្ធរណ៍របស់ខ្លួនជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី ៥ ខែឧសភា ឆ្នាំ ២០២០ ឯកសារ D267/27 កថាខណ្ឌ ២៦-៣២។

[26] អនុលោមតាមវិធាន ៧៦(៥) នៃវិធានផ្ទៃក្នុង កិច្ចដែលមានវិការៈនីតិវិធី ត្រូវចាត់ទុកជាមោឃៈ និង ត្រូវដកចេញពីសំណុំរឿង ហើយត្រូវបានហាមឃាត់មិនឲ្យយកមកប្រើប្រាស់ជាការយោងប្រឆាំងនឹងវិការៈនោះឡើយ។ នៅក្រោមក្របខណ្ឌច្បាប់ និង យុត្តិ

ខ. សេចក្ដីថ្លែងសាររបស់ អ.ជ.ស.ដ. ចុះថ្ងៃទី ៣ ខែមេសា ឆ្នាំ ២០២០ ភាពនៅស្ងៀមស្ងាត់ និង ការបញ្ជូនត្រឡប់វិញនូវសារណាសុំការពិចារណារបស់ ស.ព.អ. គឺពុំមែនជា "សេចក្ដីសម្រេច" ដែលអាចប្ដឹងសាទុក្ខ មានអនុភាពបញ្ចប់ដំណើរការនីតិវិធីអនុលោមតាមវិធាន ១០៤(៤) នោះទេ។ ដោយសារ អ.ជ.ស.ដ. មិនដែលបានទទួលរឿងក្ដី ០០៤/២ នោះ អ.ជ.ស.ដ. មិនអាចបញ្ចប់ដំណើរការនីតិវិធី នៅពេលថ្លែងថា "ការចេញសេចក្ដីសម្រេចជាផ្លូវការមួយរបស់ អ.ជ.ស.ដ. មិនអាចធ្វើទៅបាន"[27]។ ចៅក្រមជាតិ និង អន្តរជាតិនៃ អ.ជ.ស.ដ. មិនអាចយល់ស្របគ្នាទៅលើករណីថា តើ អ.ជ.ស.ដ. មានសិទ្ធិអំណាចពិសេស ដើម្បីពោលប្រាស្រ័យលើបញ្ហានានា ដែលលើកឡើងនៅក្នុងសារណាសុំការពិចារណារបស់ភាគីនៅក្នុងរឿងក្ដី ០០៤/២ ឬទេ និង បានថ្លែងយ៉ាងច្បាស់លាស់ថា សេចក្ដីថ្លែងការណ៍របស់ខ្លួន "ពុំមានអនុភាពផ្លូវច្បាប់"[28]។

គ. អ.ជ.ត.ក. ពុំមែនជា "ស្ថាប័ននីតិបុគ្គលតែមួយគត់ដែលអាចរក្សាសុចរិតភាពនៃដំណើរការនីតិវិធី និង អាចការពារផលប្រយោជន៍យុត្តិធម៌"[29] បែបនោះទើបវាចាំបាច់ត្រូវអនុវត្តយុត្តាធិការដែលជាប់ជាមួយដើម្បីស្ដាប់បណ្ដឹងសាទុក្ខជាបន្ទាន់របស់ ស.ព.អ.។ អ.ប.ជ. កំពុងមានរឿងក្ដី ០០៤/២ ក្នុងដៃនៅឡើយ។ អនុលោមតាមមាត្រា ៦០៦(១) នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា "គ្រប់ការលំបាកក្នុងការបកស្រាយសេចក្ដីសម្រេចរបស់តុលាការ ត្រូវដាក់ជូនតុលាការ

---

សាស្ត្ររបស់ អ.វ.ត.ក. ឧបាស្រ័យដែលអាចធ្វើទៅបាន បន្ទាប់ពីមោឃភាពរួចមក រួមមាន ការបង្វិលដីកាដំណោះស្រាយត្រឡប់ទៅឲ្យ ស.ច.ស. វិញ ដោយមានសេចក្ដីបង្គាប់ឲ្យចេញដីកាដំណោះស្រាយតែមួយ ឬ ឲ្យ អ.ប.ជ. ធ្វើការស៊ើបអង្កេតរឿងក្ដីដោយខ្លួនឯង និង ចេញដីកាដំណោះស្រាយដោយផ្ទាល់។ ក្នុងកាលៈទេសៈពិសេសបច្ចុប្បន្ននេះ ដែលការបង្វិលដីកាដំណោះស្រាយត្រឡប់ទៅវិញមិនអាចអនុវត្តបាន ឬ មិនអលទ្ធភាពនោះ អ.ប.ជ មិនអាចឈានដល់ការឯកភាពជាឯកច្ឆន្ទ ដើម្បីចេញដីកាដំណោះស្រាយដែលកែសម្រួលបានទេ នោះទ្រឹស្ដីស្ដីពីការរំលោភនីតិវិធី - ជាវិធាននីតិវិធីដែលបានបង្កើតនៅកម្រិតអន្តរជាតិ - អាចត្រូវបានយកមកប្រើប្រាស់ ដើម្បីផ្អាកដំណើរការនីតិវិធីជាអចិន្ត្រៃយ៍។ *សូមមើល* សារណាបន្ថែមរបស់ មាស មុត ទៅលើបណ្ដឹងឧទ្ធរណ៍របស់ខ្លួនជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី ៥ ខែឧសភា ឆ្នាំ២០២០ ឯកសារ D267/27 កថាខណ្ឌ ៣៣-៤៩។

[27] សេចក្ដីថ្លែងការណ៍របស់ អ.ជ.ស.ដ. ចុះថ្ងៃទី ៣ ខែមេសា ឆ្នាំ ២០២០ ទំព័រ ៤។

[28] សេចក្ដីថ្លែងការណ៍របស់ អ.ជ.ស.ដ. ចុះថ្ងៃទី ៣ ខែមេសា ឆ្នាំ ២០២០ ទំព័រ ៤។

[29] បណ្ដឹងសាទុក្ខជាបន្ទាន់របស់ ស.ព.អ. កថាខណ្ឌ ៤៨។

*ដែលបានប្រកាសសេចក្តីសម្រេចនោះពិនិត្យ*”[30]។

ឃ. បើទោះជា អ.ជ.ត.ក. សម្រេចថា ខ្លួនមានយុត្តាធិការក្នុងការស្តាប់បណ្តឹងសាទុក្ខជាបន្ទាន់របស់ ស.ព.អ. ក្តី ក៏ អ.ជ.ត.ក. ពុំមានយុត្តាធិការលើរឿងក្តី ០០៤/២ នេះឡើយ។ អ.ជ.ត.ក ពុំមានយុត្តាធិការក្នុងការពិនិត្យឡើងវិញលើការសម្រេចរបស់ អ.ប.ជ. ដែលថា ដីកាដំណោះស្រាយទាំងពីរត្រូវបានចេញដោយខុសច្បាប់ ហើយ ជាផលវិបាក គឺនាំឱ្យមោឃៈនិងឥតបានការ[31] ឬ ក្នុងការចេញសេចក្តីសម្រេច ឬ ដីកា*ណាមួយ* ដែលមានអនុភាពត្រូវគោរពនិងអនុវត្តឡើយ។ អ.ជ.ត.ក. ក៏មិនអាចចេញមតិផ្តល់យោបល់ប្រឹក្សា ជាពិសេស ដែល ស.ព.អ. ពុំបានស្នើសុំនោះដែរ។ អ.ជ.ត.ក. អាចមានត្រឹមតែសមត្ថកិច្ចក្នុងការផ្តល់ការជញ្ជឹគិតទាំងឡាយ ដែលគ្មានអនុភាពផ្លូវច្បាប់ ដូចគ្នានឹងសេចក្តីថ្លែងសាររបស់ អ.ជ.ស.ជ. ចុះថ្ងៃទី ៣ ខែមេសា ឆ្នាំ ២០២០ ដែរ។

**ខ. ពុំមានគោលជំហរដើម នៅក្រោមក្របខណ្ឌ អ.វ.ត.ក. ដែលបញ្ជូនរឿងក្តីទៅជំនុំជម្រះ នៅពេល ស.ច.ស. ចេញដីកាដំណោះស្រាយផ្ទុយគ្នាដោយខុសច្បាប់**

១២. ស.ព.អ. អះអាងថា អ.ជ.ស.ជ. ខកខានមិនបានផ្តល់អនុភាពលើគោលជំហរដើម ដែលថា កាលណា ស.ច.ស. ខ្វែងយោបល់គ្នាលើការបញ្ជូនរឿងក្តីទៅមុខ រឿងក្តីនោះត្រូវបន្តទៅដំណាក់កាលបន្ទាប់ ប្រសិនបើមិនមានសំឡេងភាគច្រើនលើសលុបរបស់ អ.ប.ជ. ដើម្បីរារាំងដំណើរការទៅមុខរបស់វានោះ ដែលមានបង្កប់នៅក្នុង៖ **ក.** កិច្ចព្រមព្រៀង និង ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.[32]

[30] *រឿងក្តី នួន ជា និង ជនផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ជ/អ.ជ.ត.ក (១៦) សេចក្តីសម្រេចលើសំណើរបស់អង្គជំនុំជម្រះសាលាដំបូង និង មេធាវីការពារក្តី អៀង ធីរិទ្ធ សុំការណែនាំ និង ការបញ្ជាក់បំភ្លឺ ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០១៣ ឯកសារ E138/1/10/5/8/2 កថាខណ្ឌ ៨ ដែលបានដកស្រង់មាត្រា ៦០៦(១) នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា (ការគូសបញ្ជាក់បន្ថែម)។

[31] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៤/២ ទំព័រ ៨៩។ *សូមមើល ផងដែរ* កថាខណ្ឌ ១១(ក) *ខាងលើ* ។

[32] បណ្តឹងសាទុក្ខជាបន្ទាន់របស់ ស.ព.អ. កថាខណ្ឌ ៥១។

**ខ.** វិធាន ៧៧(១៣)(ខ)[33] **គ.** វិធាន ៧៩(១)[34] និង **ឃ.** គោលបំណងនៃកិច្ចព្រមព្រៀង និង ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.[35]។

១៣. ប្រសិនបើអនុញ្ញាតឲ្យធ្វើអន្តរាគមន៍ មេធាវីការពារក្តីស្នើសុំឲ្យពិចារណាថា៖

ក. គោលជំហរ "ដើម" នៅក្នុងកិច្ចព្រមព្រៀង និង ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ថា "ការស៊ើបអង្កេតត្រូវបន្តទៅមុខ" កាលណាសហព្រះរាជអាជ្ញា ឬ ស.ច.ស. ខ្វែងយោបល់គ្នាលើដំណើរការរឿងក្តីទៅមុខ និង អ.ប.ជ. មិនអាចរកសំឡេងភាគច្រើនលើសលុប គឺអនុវត្តតែនៅក្នុងដំណាក់កាល *ស៊ើបអង្កេត*ប៉ុណ្ណោះ[36]។ *មិនមែនជាខ្លឹមសារសំខាន់* (abiter dictum) របស់ អ.ជ.ត.ក. ទាក់ទងនឹងការខ្វែងយោបល់គ្នារវាង ស.ច.ស. នៅក្នុងបរិបទនៃយន្តការដោះស្រាយវិវាទ *នៅមុនពេល* ស.ច.ស. ចេញដីកាដំណោះស្រាយ - គឺថា នៅពេល"*ស្នើ* ឲ្យចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬ ដីកាលើកលែងការចោទប្រកាន់"[37] ដូចដែល ស.ព.អ. ទទួលស្គាល់នោះទេ[38]។ "លទ្ធផលជាសារធាតុរបស់ អ.ជ.ត.ក."[39] មិនអាចអនុវត្តដូចគ្នាចំពោះស្ថានភាពដែល ស.ច.ស. *ចេញដោយខុសច្បាប់*នូវដីកាដំណោះស្រាយផ្ទុយគ្នា ដោយសារពុំមានដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលអាចបញ្ជូនរឿងក្តីទៅជំនុំជម្រះនោះឡើយ[40]។

ខ. បើទោះជាវិធាន ៧៧(១៣)(ខ) ត្រូវបានចាត់ទុកជា *ច្បាប់ពិសេស ដូចនឹង* វិធាន ៧៧(១៣)(ក) ក៏វិធានទាំងពីរត្រូវបានរៀបចំឡើងសម្រាប់ការចេញដីកាដំណោះស្រាយតែមួយ និង អ.ប.ជ.

---

[33] បណ្តឹងសាទុក្ខជាបន្ទាន់របស់ ស.ព.អ. កថាខណ្ឌ ៥២-៥៤។

[34] បណ្តឹងសាទុក្ខជាបន្ទាន់របស់ ស.ព.អ. កថាខណ្ឌ ៥៥។

[35] បណ្តឹងសាទុក្ខជាបន្ទាន់របស់ ស.ព.អ. កថាខណ្ឌ ៥៦។

[36] *សូមមើល* ចម្លើយរបស់ មាស មុត តបទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ២០១៩ ឯកសារ D266/5 កថាខណ្ឌ ១៩។ ការឆ្លើយតបរបស់មាស មុត ទៅនឹងចម្លើយរបស់សហព្រះរាជអាជ្ញាអន្តរជាតិតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់ដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី ១៩ ខែសីហា ឆ្នាំ ២០១៩ ឯកសារ D267/12 កថាខណ្ឌ ៣៥។

[37] *រឿងក្តី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ត.ក សាលដីកា ចុះថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28 កថាខណ្ឌ ៦៥ (ការគូសបញ្ជាក់បន្ថែម)។

[38] បណ្តឹងសាទុក្ខជាបន្ទាន់របស់ ស.ព.អ. កថាខណ្ឌ ៥៣។

[39] បណ្តឹងសាទុក្ខជាបន្ទាន់របស់ ស.ព.អ. កថាខណ្ឌ ៥៤។

[40] *សូមមើល* កថាខណ្ឌ ១១(ក) *ខាងលើ*។

បានសម្រេចជាឯកច្ឆ័ន្ទថា ដីកាដំណោះស្រាយទាំងពីរត្រូវបានចេញដោយខុសច្បាប់[41]។

គ. វិធាន ៧៩(១) ដូចវិធាន ៧៧(១៣)(ខ) ត្រូវបានបង្កើតឡើងសម្រាប់ដីកាដំណោះស្រាយតែមួយ ពុំមែនសម្រាប់ដីកាដំណោះស្រាយដែលផ្ទុយគ្នានោះទេ[42]។ ការប្រើពាក្យ "ឬ" នៅក្នុងវិធាន ៧៩(១) ចង្អុលបង្ហាញតែចំពោះករណីដែលថា អ.ជ.ស.ដ. អាចត្រូវបានប្តឹងសុំឱ្យទទួលយកសំណុំរឿងតាមរយៈដីកា "ពី [ស.ច.ស.]" ប្រសិនបើ អ.ប.ជ. ពុំចេញដីកាដំណោះស្រាយដែលបានកែប្រែលើបណ្តឹងឧទ្ធរណ៍[43]។ វាពុំមានន័យថា អ.ជ.ស.ដ. អាចត្រូវបានប្តឹងសុំឱ្យទទួលយកដីកាបញ្ជូនរឿងទៅជំនុំជម្រះដោយខុសច្បាប់នោះទេ។ ពុំមានដីកាបញ្ជូនរឿងទៅជំនុំជម្រះ "ផ្ទាល់" ដែលបានប្តឹងមក អ.ជ.ស.ដ. ទេ ដោយសារដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលបានចេញដោយខុសច្បាប់ នៅក្នុងរឿងក្តី ០០៤/២ ត្រូវបានចាត់ទុកជាមោឃៈនិងឥតបានការ[44]។

ឃ. ភាគីទាំងឡាយនៃកិច្ចព្រមព្រៀង និង អ្នកព្រាងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ពុំយល់ស្របនឹងការបញ្ជូនរឿងក្តីទៅជំនុំជម្រះ នៅពេល ស.ច.ស. ចេញដីកាដំណោះស្រាយផ្ទុយគ្នាឡើយ[45]។

---

[41] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៤/២ ទំព័រ ៨៩។ បណ្តឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី ៨ ខែមេសា ឆ្នាំ ២០១៩ ឯកសារ D267/4 កថាខណ្ឌ ៤១-៤៨។ ចម្លើយរបស់ មាស មុត តបទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ២០១៩ ឯកសារ D266/5 កថាខណ្ឌ ១៧។ ការឆ្លើយតបរបស់ មាស មុត ទៅនឹងចម្លើយរបស់សហព្រះរាជអាជ្ញាអន្តរជាតិតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី ១៩ ខែសីហា ឆ្នាំ ២០១៩ ឯកសារ D267/12 កថាខណ្ឌ ៣១។

[42] *សូមមើល* ការឆ្លើយតបរបស់ មាស មុត ទៅនឹងចម្លើយរបស់សហព្រះរាជអាជ្ញាអន្តរជាតិតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី ១៩ ខែសីហា ឆ្នាំ ២០១៩ ឯកសារ D267/12 កថាខណ្ឌ ៤០។

[43] វិធាន ៧៩(១) ចែងថា៖ "អង្គជំនុំជម្រះសាលាដំបូង ទទួលបណ្តឹងដោយដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេត ឬតាមសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ"។

[44] *សូមមើល* កថាខណ្ឌ ១១(ក)*ខាងលើ*។

[45] *សូមមើល* បណ្តឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី ៨ ខែមេសា ឆ្នាំ ២០១៩ ឯកសារ D267/4 កថាខណ្ឌ ៣៣-៤០។ ការឆ្លើយតបរបស់ មាស មុត ទៅនឹងចម្លើយរបស់សហព្រះរាជអាជ្ញាអន្តរជាតិតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី ១៩ ខែសីហា ឆ្នាំ ២០១៩ ឯកសារ D267/12 កថាខណ្ឌ ៣៦-៣៨។

### គ. អ.ជ.ស.ដ. ពុំមានកំហុសអង្គច្បាប់ ឬ រំលោភឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការមិនអនុវត្តសិទ្ធិអំណាចពិសេសរបស់ខ្លួនឡើយ

១៤. ស.ព.អ. អះអាងថា អ.ជ.ស.ដ. មានកំហុសអង្គច្បាប់ និង រំលោភឆន្ទានុសិទ្ធិ នៅពេលខ្លួនបដិសេធមិនអនុវត្តសិទ្ធិអំណាចពិសេស ដើម្បីសម្រេចលើបញ្ហាដែលអាចយកមកជំនុំជម្រះនៅចំពោះមុខខ្លួន ដោយសន្និដ្ឋានថា ខ្លួនពុំមានសិទ្ធិអំណាចធ្វើសេចក្តីសម្រេចលើរឿងក្តី ០០៤/២ នោះឡើយ[46]។

១៥. ប្រសិនបើអនុញ្ញាតឲ្យធ្វើអន្តរាគមន៍ មេធាវីការពារក្តីស្នើសុំឲ្យពិចារណាថា អ.ជ.ស.ដ. ពុំមានកំហុសអង្គច្បាប់ ឬ មិនបានរំលោភឆន្ទានុសិទ្ធិ ដោយការមិនអនុវត្តសិទ្ធិអំណាចពិសេស ដោយសារអនុលោមតាមក្របខណ្ឌ អ.វ.ត.ក. ចៅក្រមនៃ អ.ជ.ស.ដ. ពុំត្រូវបានបង្គាប់បង្ខំឲ្យយល់ស្របតាមឡើយ[47]។ អនុលោមតាមមាត្រា ៤(១)(ក) នៃកិច្ចព្រមព្រៀង "ចៅក្រមត្រូវ*ព្យាយាម*ដើម្បីឈានទៅដល់ការមូលមតិគ្នាជាឯកច្ឆ័ន្ទ នៅក្នុងការសម្រេចសេចក្តីរបស់ខ្លួន" ហើយប្រសិនបើមិនអាចទេ នោះសេចក្តីសម្រេចរបស់ អ.ជ.ស.ដ. តម្រូវឲ្យមានសំឡេងភាគច្រើនលើសុលបយ៉ាងហោចណាស់ពីចៅក្រមចំនួន ៤ ក្នុងចំណោមចៅក្រមចំនួន ៥ នាក់[48]។ ខណៈដែលចៅក្រមអន្តរជាតិនៃ អ.ជ.ស.ដ. មានសិទ្ធិក្នុងការបញ្ចេញទស្សនៈរបស់ខ្លួនថា អ.ជ.ស.ដ. មានសិទ្ធិអំណាចពិសេស ដើម្បីពោលប្រាស្រ័យលើបញ្ហានានា ដែលលើកឡើងនៅក្នុងសារណាសុំការពិចារណារបស់ភាគីនានានៅក្នុងរឿងក្តី ០០៤/២ ក្តី ក៏ចៅក្រមជាតិនៃ អ.ប.ជ. មានសិទ្ធិស្មើគ្នាក្នុងការថ្លែងទស្សនៈរបស់ខ្លួនថា អ.ជ.ស.ដ. ពុំមានសិទ្ធិអំណាចធ្វើសេចក្តីសម្រេចឡើយ ដោយសារ អ.ជ.ស.ដ. ពុំត្រូវបានប្តឹងសុំឲ្យទទួលរឿងក្តី[49]។ ក្នុងករណីពុំមានការព្រមព្រៀងពីចៅក្រមជាតិ និង អន្តរជាតិនៃ អ.ជ.ស.ដ. ទេនោះ អ.ជ.ស.ដ. ពុំអាចចេញសេចក្តីសម្រេចបានទេ។

## III. សេចក្តីសន្និដ្ឋាន និង សំណើសុំ

១៦. ដោយហេតុថា ដីកាដំណោះស្រាយត្រូវចាត់ទុកជាមោឃៈនិងឥតបានការ ហើយ អ.ប.ជ. កំពុងកាន់រឿងក្តី ០០៤/២ ក្នុងដៃ នោះ អ.ជ.ត.ក. ពុំមានយុត្តាធិការស្តាប់បណ្តឹងសាទុក្ខជាបន្ទាន់របស់

---

[46] បណ្តឹងសាទុក្ខជាបន្ទាន់របស់ ស.ព.អ. កថាខណ្ឌ ៥៨-៥៩។

[47] *សូមមើល* មាត្រា ៤(១)(ក) នៃកិច្ចព្រមព្រៀង។

[48] ការគូសបញ្ជាក់បន្ថែម។

[49] សេចក្តីថ្លែងការណ៍របស់ អ.ជ.ស.ដ ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០២០ ទំព័រ ៣-៤។

ស.ព.អ. ហើយពុំមានយុត្តាធិការចេញសេចក្តីសម្រេច*ណាមួយ* ដែលមានអនុភាពបង្ខំឱ្យគោរពនិងអនុវត្តតាមនោះឡើយ។ បើទោះជា អ.ជ.ត.ក. បើកសវនាការលើបណ្តឹងសាទុក្ខជាបន្ទាន់របស់ ស.ព.អ. ក្តី នោះ អ.ជ.ត.ក. អាចមានសមត្ថភាពត្រឹមផ្តល់ការជញ្ជឹងគិត ដែលពុំមានអនុភាពផ្លូវច្បាប់តែប៉ុណ្ណោះ។ អ.ជ.ត.ក. គួរអនុញ្ញាតឱ្យមេធាវីការពារក្តីធ្វើអន្តរាគមន៍ និង ឆ្លើយតបទៅនឹងទឡ្ហីករណ៍ផ្លូវច្បាប់ដោយឡែកដូចបានគូសបញ្ជាក់ខាងលើ ដែលជាប្រយោជន៍ស្របច្បាប់របស់លោក មាស មុត។ ការខកខានមិនឱ្យគាត់បង្ហាញ មុនពេលចេញសេចក្តីសម្រេចលើបណ្តឹងសាទុក្ខជាបន្ទាន់របស់ ស.ព.អ. - ដែលកំណត់ថាតើរឿងក្តីរបស់គាត់ត្រូវបញ្ជូនទៅជំនុំជម្រះ ឬ ច្រានចោល - នឹងបង្កព្យសនកម្មដល់គាត់ ហើយបង្កការខូចខាតដែលមិនអាចជួសជុលបាន ទៅលើសិទ្ធិរបស់គាត់ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ និង ដំណើរការសមស្រប[50]។

អាស្រ័យហេតុនេះ សម្រាប់ហេតុផលដែលបានជម្រាបជូនខាងលើនេះ មេធាវីការពារក្តីគោរពស្នើសុំ អ.ជ.ត.ក. មេត្តា ៖

ក. **ទទួលយក** សំណើសុំធ្វើអន្តរាគមន៍នេះ។ និង

ខ. **អនុញ្ញាត** ឱ្យមេធាវីការពារក្តីធ្វើអន្តរាគមន៍នៅក្នុងរឿងក្តី ០០៤/២ និង ឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខជាបន្ទាន់របស់ ស.ព.អ. នៅក្នុងរឿងក្តី ០០៤/២។

សូមលោកចៅក្រមទទួលយកសេចក្តីគោរពអំពីយើងខ្ញុំ។

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **២៩** ខែ**ឧសភា** ឆ្នាំ **២០២០**

**សហមេធាវីការពារក្តីលោក មាស មុត**

| | |
|---|---|
| អាង ឧត្តម | Michael G. KARNAVA |

[50] *សូមមើល* ជើងទំព័រ ១២ *ខាងលើ* ។